គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ...៧៦០.៣៥៧/គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី.១៩. ខែ.មេសា.ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** ស្តីពីក្របខ័ណ្ឌសកម្មភាពសេវាសង្គមនៅថ្នាក់ក្រោមជាតិ

**យោង៖** ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីចូលរួមចំណែកក្នុងការពង្រឹងដល់ការផ្តល់សេវាផ្នែកសង្គម នៅថ្នាក់ក្រោមជាតិទទួលបានប្រសិទ្ធភាព និងគុណភាពខ្ពស់ ដៃគូអភិវឌ្ឍមួយចំនួនបានអនុវត្តកម្មវិធីតាមក្របខ័ណ្ឌ នៃវិធីសាស្ត្រផ្អែកតាមកម្មវិធីផអព ក្នុងការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស ដើម្បីធ្វើឱ្យគណៈកម្មាធិការទាំងនោះមានសមត្ថភាពគ្រប់គ្រាន់ និងមធ្យោបាយសមស្រប សម្រាប់ចូលរួមចំណែកដោះស្រាយ និងកែលំអគុណភាពសេវាសង្គមសម្រាប់កុមារ ក្រុមជនងាយរងគ្រោះ និងស្ត្រី តាមរយៈប្រព័ន្ធផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងលើការអនុវត្តការងារផ្នែកសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅបង្កិតសេវាសង្គមឱ្យកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ថវិកាទាំងនោះ បានធ្វើការវិភាជន៍មួយផ្នែកទៅក្នុងកញ្ចប់ថវិការបស់រាជធានី ខេត្ត ដើម្បីឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការជំរុញ សម្របសម្រួល និងគាំទ្រដល់ការអនុវត្តការងារផ្នែកសេវាសង្គម ក្នុងគោលដៅលើកកម្ពស់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងចូលរួមកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងមួយផ្នែកទៀតវិភាជន៍ទៅឱ្យឃុំ សង្កាត់ ។

ដើម្បីធានាឱ្យមានការប្រើប្រាស់ថវិកា និងសកម្មភាពនៅថ្នាក់ក្រោមជាតិ ចំគោលដៅ ទទួលបានគុណភាព និងប្រសិទ្ធភាពខ្ពស់ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំពីរបៀបនៃការប្រើប្រាស់ថវិកាខាងលើនេះ ដូចខាងក្រោម៖

**១- ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ថវិកាដែលគាំទ្រដល់ការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការពិគ្រោះយបល់ស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថវិកានេះគឺមួយចំនួនសម្រាប់គាំទ្រ និងប្រើប្រាស់ក្នុងការរៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការ និងមួយចំនួនទៀត សម្រាប់ប្រើប្រាស់ក្នុងការចុះគាំទ្រដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គោលដៅ។

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel : (855-23) 720 061 / 720 038

ចំពោះថវិកាដែលគាំទ្រដល់មន្ត្រីទទួលបន្ទុកសេវាសង្គមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថវិកាទាំងនោះ ត្រូវប្រើប្រាស់សម្រាប់មន្ត្រីសេវាសង្គម ចុះសម្របសម្រួល និងគាំទ្រការអនុវត្តការងារផ្នែកសេវាសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គោលដៅ។

**២- ឃុំ សង្កាត់គោលដៅ**

នៅក្នុងឆ្នាំអនុវត្តកន្លងមក ដោយមិនមានការណែនាំលំអិតពីការគាំទ្រលើការអនុវត្តសកម្មភាព រវាងភ្នាក់ងារអនុវត្ត និងភាគីអ្នកគាំទ្រដល់ការអនុវត្តសេវាសង្គមនៅមូលដ្ឋានឃុំ សង្កាត់គោលដៅ ដែលធ្វើឱ្យការអនុវត្តសកម្មភាពមានភាពស្មុគស្មាញ និងរាំងស្ទះដល់ដំណើរ នៃការផ្តល់សេវាដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូច្នេះដើម្បីពង្រឹង និងលើកកម្ពស់ដល់ការផ្តល់សេវានៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព ឃុំ សង្កាត់គោលដៅនីមួយៗត្រូវដាក់បញ្ចូលផែនការសកម្មភាព និងថវិកាទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំនីមួយៗរបស់ខ្លួន។ ចំពោះសកម្មភាពសម្រាប់អនុវត្តការងារផ្នែកសេវាសង្គមនៅមូលដ្ឋានឃុំ សង្កាត់គោលដៅ មានលំអិតក្នុងឧបសម្ព័ន្ធដែលជូនភ្ជាប់មកជាមួយ។

ចំពោះថវិកាដែលគាំទ្រផ្នែកសេវាសង្គមដែលនៅសល់ពីការអនុវត្តពីឆ្នាំកន្លងមក (ឆ្នាំ២០១១) ឃុំ សង្កាត់ ត្រូវបន្តប្រើប្រាស់ថវិកានេះ ដើម្បីគាំទ្រសកម្មភាព ដែលត្រូវអនុវត្តបន្ត នៅក្នុងឆ្នាំបន្ទាប់ (ឆ្នាំ២០១២) លើសកម្មភាពដដែល ដែលបានគាំទ្រពីឆ្នាំកន្លងមក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលរាជធានី ខេត្ត ធ្វើការណែនាំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ គោលដៅ និងអ្នកពាក់ព័ន្ធនានា ក្នុងការសម្របសម្រួល និងអនុវត្តសកម្មភាពផ្នែកសេវាសង្គមនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ ពីខ្ញុំ។

**ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**<u>ចម្លងជូន</u>**

- ក្រសួងមហាផ្ទៃ(ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២នៃផអ៣)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី៤នៃផអ៣)
- អគ្គនាយកដ្ឋានរតនាគារជាតិ
- រតនាគាររាជធានី ខេត្ត
- ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈកម្មាធិការនានា របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អង្គការយូនីសេហ្វ
- អង្គការយូអិនអេហ្វភីអេ
- ឯកសារ-កាលប្បវត្តិ